**មាត្រា ៧** : ក្រសួងការពារជាតិ ត្រូវបើករបបឧបត្ថម្ភដល់កងជីវពលដូចខាងក្រោម :

១-កងជីវពលការពារ និង ប្រតិបត្តិការផ្តល់របបម្ហូបប្រចាំថ្ងៃដូចកងយោធពល និង ផ្តល់ជាប្រាក់សំរាប់ទិញអង្ករដោយខ្លួនឯង ។

២-កងជីវពលឃុំ ផ្តល់ជាប្រាក់សំរាប់ទិញអង្ករ ១៨ គីឡូក្រាម និងអំបិល ២ គីឡូក្រាម ១ខែ ។

**មាត្រា ៨** : បទបញ្ញត្តិទាំងឡាយណា ដែលមានន័យខ្ទឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ជានិរាករណ៍ ។

**មាត្រា ៩** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង បណ្តាក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ : ១៨ អនក្រ.បក

## ស្តីពីការបង្កើតគណៈកម្មាធិការនីតិកម្ម នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល ។

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ តាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤/៩៦/២៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត « អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន » ដែលជំនួសអោយព្រះរាជក្រឹត្យ លេខ នស/រកត/០២៩៥/១៩ ចុះថ្ងៃទី ២៥ កុម្ភៈ ឆ្នាំ ១៩៩៥ ។
- យោងតាមសំណូមពរការងារចាំបាច់ ។

## សំរេច

**មាត្រា ១** : បង្កើតគណៈកម្មាធិការនីតិកម្ម ស្តីពីកិច្ចការព្រំដែនចំណុះអោយអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **វ៉ា គឹមហុង** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ទទួលបន្ទុកកិច្ចការព្រំដែន | ប្រធាន |
| ២-លោក **ភ្លួង ហ្វ្លរ** | ទីប្រឹក្សាច្បាប់របស់រាជរដ្ឋាភិបាល | ទីប្រឹក្សា |
| ៣-ឯកឧត្តម **អ៊ុង ស៊ាន** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤-ឧត្តមសេនីយ៍ត្រី **រស់ គឹមសាន** | ប្រធាននាយកដ្ឋានភូមិសាស្ត្រ នៃក្រសួងការពារជាតិ | សមាជិក |
| ៥-ឯកឧត្តម **សេង រ៉ុន** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦-លោក **ម៉ៅ ផាត់** | ទីប្រឹក្សាច្បាប់ក្រសួងយុត្តិធម៌ | សមាជិក |

៧-លោក **ឡុង ផុល** ប្រធាននាយកដ្ឋានច្បាប់-កុងស៊ុលនៃ
ក្រសួងការបរទេសនិងសហប្រតិបត្តិការ
អន្តរជាតិ សមាជិក

៨-លោក **ឡាយ ប៊ុនសុខ** ប្រធាននាយកដ្ឋានទាក់ទងអន្តរជាតិ នៃ
ក្រសួងការពារជាតិ សមាជិក

៩-លោក **សុខ ជីវគុណា** ប្រធាននាយកដ្ឋានភូតព្ភសាស្ត្ររ៉ែនៃក្រសួង
ឧស្សាហកម្មរ៉ែនិងថាមពល
សមាជិក

១០-លោក **ប្រាក់ ស:រឿន** អនុប្រធាននាយកដ្ឋានជនបរទេសនៃ
អគ្គនាយកដ្ឋាននគរបាលជាតិនៃ ក្រសួង
មហាផ្ទៃ សមាជិក

១១-លោក **ម:ៈ សាវ៉ាង** អនុប្រធាននាយកដ្ឋានភូមិសាស្ត្រ នៃទីស្តី
ការគណៈរដ្ឋមន្ត្រី សមាជិក

១២-លោក **ហេម គ្រាញ់តូនី** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៣-លោក **ស៊ា កុសល** ប្រធានការិយាល័យសន្ធិសញ្ញាក្រសួងការបរ
ទេសនិងសហប្រតិបត្តិការអន្តរជាតិ
លេខាធិការ

១៤-លោក **កុលិន្ទ មុនី** មន្ត្រីនាយកដ្ឋានអាស៊ីទទួលបន្ទុកវៀតណាម
នៃក្រសួងការបរទេសនិងសហប្រតិបត្តិការ
អន្តរជាតិ អនុលេខាធិការ

១៥-លោក **ហូ ពេជ្រមោលី** មន្ត្រីនាយកដ្ឋានច្បាប់-កុងស៊ុលនៃក្រសួង
ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
អនុលេខាធិការ

១៦-លោក **អួន ណារ៉ុំ** មន្ត្រីនាយកដ្ឋានច្បាប់-កុងស៊ុលនៃក្រសួង

ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

អនុលេខាធិការ

**មាត្រា ២ :** គណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែននេះ មានភារកិច្ច :

- ស្រាវជ្រាវ ដើម្បីរៀបចំឯកសារជាលក្ខណៈច្បាប់ (ទាំងព្រំដែនគោកទាំងព្រំដែនសមុទ្រជាមួយប្រទេសជិតខាង) សំរាប់យកទៅតំកល់នៅអង្គការសហប្រជាជាតិ និងធ្វើជាមូលដ្ឋានបង្អែកសំរាប់ពិភាក្សាជាមួយប្រទេសជិតខាង ។
- ធ្វើការចរចាជាមួយប្រទេសជិតខាង ក្នុងការតំណត់ជ្រើសរើសយកផែនទីសំរាប់ធ្វើការវាស់វែងខ្សែបន្ទាត់ព្រំដែន ។
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន ទៅអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា ៣ :** គណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែននេះ មានលេខាធិការដ្ឋានសំរាប់ជំនួយការរដ្ឋបាលនិងសំរបសំរួលការងារបច្ចេកទេសដែលមានទីស្នាក់ការនៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដែលមានឯកឧត្តម អ៊ុំ ស៊ាន ជាប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការនីតិកម្ម ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។ លេខាធិការដ្ឋាននៃគណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែននេះ ជាផ្នែកមួយនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដែលមានទីតាំងនៅនាយកដ្ឋានភូមិសាស្ត្រនៃទីស្តីការគណៈរដ្ឋមន្ត្រី ។ លេខានៃលេខាធិការដ្ឋាននៃគណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែននេះ ត្រូវជាសមាជិកនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង ក្រសួងពាក់ព័ន្ធ ព្រមទាំង ឯកឧត្តម អស់លោក សាមីជន ដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ៥ :** អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានិងចុះហត្ថលេខា តទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណប្ញទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ១៩ អនក្រ.បក

## ស្ដីពីការបង្កើតគណៈកម្មាធិការបច្ចេកទេស ស្ដីពីកិច្ចការព្រំដែន

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហា ក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋា ភិបាល ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា